# CHRISTIE'S CHARITY AUCTION 2014


Ms. Madeleine de Langalarie

## ឱកាសដ៏កម្រមួយដែលសិល្បករ និងវិចិត្រករទាំងអស់ទន្ទឹងរង់ចាំ ដើម្បីបង្ហាញនូវស្នាដៃសិល្បៈរបស់ខ្លួនបានមកដល់ទៀតហើយ ជាមួយនឹងកម្មវិធី ReCreation











> "ខ្ញុំចង់ឃើញសិល្បករ និងវិចិត្រករទាំងអស់ចេះរិះរកនូវមធ្យោបាយដែលជាដំណោះស្រាយរួម នៅក្នុងការធ្វើការខណៈពេលដែលមានការជាប់គាំងអ្វីមួយ"

ទស្សនិកជនដែលមានចំណាប់អារម្មណ៍ផ្នែកវិចិត្រសិល្បៈប្រាកដជាចង់ដឹងយ៉ាងខ្លាំងនូវព័ត៌មានសំខាន់ៗទាំងឡាយណា ដែលសរសេរឡើងទាក់ទងអំពីវិស័យសិល្បៈជាពិសេសក្នុងឱកាសដ៏សម្បូរបែប ដែលអនុញ្ញាតអោយពួកគេតាំងបង្ហាញ ឬក៏លក់នូវស្នាដៃដ៏វិសេសវិសាលរបស់ពួកគេ។ ដើម្បីរួមចំណែកក្នុងការផ្សព្វផ្សាយព័ត៌មានផ្នែកវិស័យសិល្បៈដែលផ្សារភ្ជាប់នឹងគំនិតច្នៃប្រឌិតនេះអោយបានកាន់តែទូលំទូលាយនៅក្នុងប្រទេសកម្ពុជាថែមទៀត ទស្សនាវដ្ដីយើងខ្ញុំក៏បានពាំនាំយកមកជូនលោកអ្នកអាននូវអត្ថបទសម្ភាសន៍មួយ ដែលបានជួបជាមួយនឹងអ្នកបង្កើត Art Agency លើកដំបូង ហើយតែមួយគត់នៅក្នុងប្រទេសកម្ពុជាដែលមានឈ្មោះថា ReCreation។ Art Agency មួយនេះជាស្ថាប័នសម្រាប់រៀបគម្រោងដាក់តាំងបង្ហាញនូវស្នាដៃរបស់វិចិត្រករ រឺសិល្បករនានា និងអាចឈានទៅកាន់ការដាក់ដេញថ្លៃទិញពីសំណាក់អ្នកចូលរួមទស្សនាផងដែរ។

មុននឹងអោយអស់លោកអ្នកជ្រាបច្បាស់អំពី Art Agency នៅក្នុងប្រទេសកម្ពុជាមួយនេះ យើងខ្ញុំសូមបង្វែរអារម្មណ៍អស់លោកអ្នកអោយស្គាល់ច្បាស់អំពីសាវតាររបស់ CHRISTIE'S បន្តិចសិន។ CHRISTIE'S ត្រូវបានគេទទួលស្គាល់ច្បាស់ ហើយចងចាំថាជាឈ្មោះ និងកន្លែងមួយដែលនិយាយអំពីស្នាដៃសិល្បៈដ៏ប្លែកៗ និងអស្ចារ្យ ហើយមានឈ្មោះបោះសំលេង និងមានប្រជាប្រិយភាពស្ទើរតែពាសពេញពិភពលោក។ យ៉ាងណាមិញ CHRISTIE'S ត្រូវបានគេបង្កើតឡើងដើម្បីជាលក្ខណៈជំនួញតែប៉ុណ្ណោះ។ ដោយប្រមើលមើលឃើញទិដ្ឋភាពទាំងអស់នេះហើយទើបធ្វើឲ្យអ្នកស្រី Madeleine បានសម្រេចចិត្តបើកសម្ពោធ Art Agency មួយនេះក្នុងប្រទេសកម្ពុជាដើម្បីជាការរួមចំណែកនៅក្នុងការលើកកម្ពស់វិស័យសិល្បៈនៅក្នុងប្រទេសកម្ពុជាដោយមានលក្ខណៈជាសប្បុរសធម៌ប្លែកអំពីប្រទេសដទៃ។ តើការលើកកម្ពស់នូវវិស័យសិល្បៈបែបលក្ខណៈសប្បុរសធម៌មានន័យយ៉ាងណាទៅវិញ? លោកអ្នកនឹងកាន់តែជ្រាបច្បាស់ថា សប្បុរសធម៌នោះជាអ្វីជាមួយយើងខ្ញុំនៅកថាខ័ណ្ឌក្រោយៗទៀត។ ឥឡូវនេះសូមលោកអ្នកស្វែងយល់អំពីប្រវត្តិរបស់ ReCreation វិញ។ ReCreation ត្រូវបានបង្កើតឡើងដំបូងបង្អស់ដោយមានអ្នកស្រី Madeleine de Langalerie នៅឆ្នាំ ២០១០។ អ្នកស្រីបានបន្តអោយដឹងទៀតថា បន្ទាប់មកដៃគូរួមការងាររបស់គាត់សព្វថ្ងៃដែលមាន Matthew Tito Cuenca ដែលជាចាងហ្វាងផ្នែកប្រព័ន្ធផ្សព្វផ្សាយ និងការងារផ្នែកទំនាក់ទំនងសាធារណៈ ហើយម្នាក់ទៀត Jean Morel គឺជាអ្នកតម្រែតម្រង់ផ្នែកមុខជំនួញស្របច្បាប់បានស្ម័គ្រចិត្តមកធ្វើសហប្រតិបត្តិការជាមួយនឹងអ្នកស្រី និងខិតខំជំរុញការងារដ៏លំបាកនេះរហូតឈានដល់គោលដៅដ៏ជោគជ័យមួយនាឆ្នាំ ២០១២ កន្លងទៅ នោះគឺការដាក់តាំងបង្ហាញជាលើកដំបូងនូវពិព័រណ៍ស្នាដៃសិល្បៈដ៏រស់រវើក ដែលមានការចូលរួមពីវិចិត្រករ និងសិល្បករក្នុង

ស្រុក និងក្រៅស្រុក។ ភាពជោគជ័យនេះគឺបានក្លាយជាគ្រឹះមួយជំរុញអោយអ្នកស្រីបន្តខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្តក្នុងការអភិវឌ្ឍន៍វិស័យសិល្បៈនៅស្រុកខ្មែរ។ អ្នកស្រីក៏បានបន្តទៀតថា៖ "គោលដៅចម្បងនៅក្នុងការបង្កើតកន្លែងសម្រាប់ដាក់តាំងបង្ហាញនូវស្នាដៃរបស់វិចិត្រករ ឬសិល្បករនានា និងមានការដាក់ដេញថ្លៃទិញពីសំណាក់អ្នកចូលរួមទស្សនាផងនេះ ដើម្បីជួយលើកកម្ពស់វិស័យសិល្បៈនៅស្រុកខ្មែរអោយកាន់តែមានភាពល្បីល្បាញថែមទៀត ពោលគឺជួយផ្សព្វផ្សាយចេញទៅក្រៅប្រទេសដើម្បីអោយពិភពលោកខាងក្រៅ ដែលជាជាតិសាសន៍ផ្សេងៗក្រៅពីខ្មែរដឹងថា ខ្មែរមានថ្វីដៃសិល្បៈល្អ មិនចាញ់ប្រទេសដទៃទៀតប៉ុន្មានទេ"។ មិនតែប៉ុណ្ណោះទេ បើនិយាយអំពីប្រទេសកម្ពុជាអ្នកស្រីមើលឃើញថា កូនខ្មែរមានជំនាញធ្វើល្អទាក់ទិននឹងការងារសិល្បៈ ពិសេសគឺទឹកដៃផ្នែកវិចិត្រកម្មនេះ តែជាអកុសលឱកាសនៃការដាក់បញ្ចេញស្នាដៃសិល្បៈរបស់ពួកគេជាសាធារណៈ ដើម្បីឲ្យទស្សនិកជនជាតិ និងអន្តរជាតិបានទស្សនា គឺនៅមានកម្រិតទាបនៅឡើយ ដូច្នេះ អ្នកស្រីត្រូវតែរិះរកគ្រប់មធ្យោបាយធ្វើយ៉ាងណាដើម្បីអោយស្នាដៃសិល្បៈរបស់ពួកគេត្រូវបានដាក់តាំងឡើង ដើម្បីទុកជាមោទនភាពដល់ពួកគេ ដែលជាម្ចាស់ស្នាដៃនេះផង ហើយដើម្បីថែរក្សា សិល្បៈខ្មែរបន្សល់ទុកតាំងពីជំនាន់បុព្វបុរសផង។ ជាងនេះទៅទៀត អ្នកស្រីក៏មានបំណងលើកទឹកចិត្ត ហើយនឹងបណ្តុះគំនិតដល់កូនខ្មែរទាំងអស់ ដែលស្រលាញ់ចូលចិត្ត និងមានជំនាញខាងផ្នែកនេះអោយខិតខំបង្កើតស្នាដៃដោយខ្លួនឯងផ្ទាល់ ដើម្បីទុកជាអត្តសញ្ញាណរបស់ខ្លួន ដោយមិនខ្វល់ថា ប្រទេសគេផ្សេងអាចធ្វើបាន ឬក៏មានរួចជាស្រេចហើយចំណែកឯយើងវិញមិនអាចធ្វើបាននោះទេ និងបន្ថែមពីលើនេះទៅទៀតគឺការចេះធ្វើការរួមគ្នាជាធ្លុងមួយ ដើម្បីឈានទៅរកជ័យជំនះ។ អ្នកស្រី ក៏បានបន្តទៀតថា៖ "ខ្ញុំចង់ឃើញសិល្បករក៏ដូចជាវិចិត្រករទាំងអស់ចេះសហការគ្នា ផ្តោះប្តូរយោបល់គ្នា និងចេះរិះរកនូវមធ្យោបាយទាំងឡាយណា ដែលជាដំណោះស្រាយរួមនៅក្នុងការធ្វើការខណៈពេលដែលមានការជាប់គាំងអ្វីមួយ។ នេះជាអ្វីដែលខ្ញុំចង់ឃើញ និងចង់បាន"។ សម្របនឹងគោលដៅដែលរៀបរាប់ខាងលើ ReCreation មានឆន្ទៈមោះមុតនៅក្នុងការជួយ និងជម្រុញរាល់ វិចិត្រករ ក៏ដូចជាសិល្បករទាំងឡាយណា ដែលមានបំណងចង់ទទួលការពិគ្រោះយោបល់ផ្ទាល់ជាមួយនឹងអ្នកឯកទេសផ្នែកឌីហ្សាញ ឬវិចិត្រករជុំវិញបញ្ហានៃការជ្រើសរើសប្រធានបទសម្រាប់សិល្បៈដែលមានការច្នៃប្រឌិតខ្ពស់។ ហើយមិនតែប៉ុណ្ណោះ ReCreation មានផ្តល់ជូនអស់លោកអ្នកនូវវគ្គបណ្តុះបណ្តាលបុគ្គលិកទូទៅ ហើយនិងបុគ្គលិកស្ម័គ្រចិត្តអំពីវិធីសាស្ត្រនៅក្នុងការតំឡើង ឧបករណ៍ផ្សេងៗបែបអ្នកជំនាញការបង្កើនការប្រើប្រាស់កម្រិតអតិបរមានៃឧបករណ៍ប្រើប្រាស់បម្រើបម្រាស់បច្ចេកវិទ្យា និងឧបករណ៍ប្រើប្រាស់ដើម្បីបង្កើនបរិមាណផលិតផលឌីហ្សាញ យុទ្ធនាការទីផ្សារ និងប្រព័ន្ធផ្សព្វផ្សាយដែលត្រូវនឹងអតិថិជនដែលបានកំនត់។ អ្វីដែលពិសេស គឺសំដៅចំពោះអ្នកដែលស្វែងរកនូវប្រភព និងការទំនាក់ទំនងជាមួយនឹងសិល្បករ និងអ្នកឌីហ្សាញដែលគាត់ពេញចិត្ត ដើម្បីជាវនូវស្នាដៃរបស់អ្នកសិល្បៈទាំងនោះតាមទឹកប្រាក់ដែលគាត់មាន និងស្នាដៃឌីហ្សាញដែលគាត់ត្រូវការផងដែរ។

**នេះគឺឱកាសមាស និងជាការដាក់តាំងពិព័រណ៍ដ៏ធំមួយនៅស្រុកខ្មែរ ដូច្នេះខ្ញុំចង់អោយយុវជនខ្មែរកូនខ្មែរបន្តមានវត្តមាននៅក្នុងកម្មវិធីបែបនេះកាន់តែច្រើនឡើងៗ**



គួរបញ្ជាក់ផងដែរថា កាលពីឆ្នាំ ២០១២ និង ២០១៣ កន្លងទៅ ReCreation បានទទួលជោគជ័យលើការរៀបចំកម្មវិធីដាក់តាំងបង្ហាញនូវស្នាដៃរបស់វិចិត្រករ និងសិល្បករនានាដែលមាននូវការដាក់ឲ្យដេញថ្លៃទិញពីសំណាក់អ្នកចូលរួមទស្សនា នៅឯសណ្ឋាគារដ៏ប្រណិតលំដាប់ផ្កាយ Sofitel។ ក្នុងឱកាសជួបជុំអ្នកសិល្បៈឌីហ្សាញ និងវិចិត្រករដ៏គគ្រឹកគគ្រេងមួយនេះ គេសង្កេតឃើញមាននូវវត្តមានសិល្បករខ្មែរចូលរួមច្រើនគួរសមដែរ ហើយស្នាដៃរបស់ពួកគាត់ខ្លះក៏ត្រូវបានភ្ញៀវបរទេសដូចជាសិង្ហបុរីជាដើម ដេញថ្លៃយកដាក់តាំងនៅប្រទេសរបស់គេផងដែរ។ អ្នកស្រី Madeleine de Langalerie បានសង្កត់ធ្ងន់ថា៖ "នេះគឺឱកាសមាស និងជាការដាក់តាំងពិព័រណ៍ដ៏ធំមួយនៅស្រុកខ្មែរ ដូច្នេះខ្ញុំចង់អោយយុវជនខ្មែរកូនខ្មែរបន្តមានវត្តមាននៅក្នុងកម្មវិធីបែបនេះកាន់តែច្រើនឡើងៗ ព្រោះថាកម្មវិធីរបៀបនេះត្រូវបានរៀបចំឡើងតាមលក្ខណៈស្តង់ដារ ពោលគឺមានភ្ញៀវអន្តរជាតិចូលរួមទស្សនា និងធ្វើការដេញថ្លៃ ហើយតាមរយៈការដេញថ្លៃយកស្នាដៃទៅតាំងនៅប្រទេសរបស់ពួកគេនេះហើយដែលអាចធ្វើអោយវប្បធម៌ និងស្នាដៃសិល្បៈខ្មែរមានពន្លឺសាយភាយដល់ប្រទេសដទៃទៀត"។ ឈរលើគោលការណ៍លើកកម្ពស់ស្នាដៃសិល្បៈកូនខ្មែរដោយសប្បុរសធម៌ អ្នកស្រីបានកំពុងតែរៀបចំកម្មវិធីតាំងពិព័រណ៍ និងដេញថ្លៃស្នាដៃសិល្បៈនេះជាលើកទី ៣ ដែលនឹងគ្រោងធ្វើឡើងរយៈពេល ៣ខែ គឺចាប់ផ្តើមពីខែមិនា ខែមេសា និងខែឧសភាខាងមុខនេះនៅឯសណ្ឋាគារ Sofitel។ ដោយការតាំងពិព័រណ៍ស្នាដៃរបស់សិល្បករ "Galerie des Arts" នឹងចាប់ផ្តើមពីថ្ងៃទី១ មិនា តទៅ ហើយការដេញថ្លៃ CHRISTIE'S Charity Auction នឹងប្រារព្ធឡើងនៅថ្ងៃទី ២៩ និង៣០ ខែមិនា ដោយមានវត្តមានលោក Lionel Gosset ជាអ្នកដំណើរការកម្មវិធីដេញថ្លៃ។

ចំពោះលក្ខន្តិកនៅក្នុងការចូលរួមដាក់តាំងបង្ហាញដេញថ្លៃ ឬក៏ចុះក្នុងទំព័រកាតាឡុករបស់ CHRISTIE'S សម្រាប់សិល្បករ និងវិចិត្រករ គឺគ្មានអ្វីលំបាកនោះទេ បើតាមអ្នកស្រី Madeleine de Langalerie គាត់បានបញ្ជាក់ប្រាប់ទស្សនាវដ្តីយើង។ អ្នកស្រីបានឲ្យដឹងថា បេក្ខជន ឬបេក្ខនារីដែលមានបំណងចង់ចូលរួមលើកគុណតម្លៃស្នាដៃរបស់ខ្លួន គឺពួកគាត់អាចផ្ញើរូបភាពដែលជាស្នាដៃដាក់តាំងរួមជាមួយការពណ៌នាដ៏ខ្លីមួយអំពីស្នាដៃ និងជីវប្រវត្តិសង្ខេបផ្ទាល់ខ្លួនរបស់ម្ចាស់ស្នាដៃមួយច្បាប់ តាមរយៈអ៊ីម៉ែលមកកាន់ខាង CHRISTIE'S សម្រាប់ការជ្រើសរើស។ បន្ទាប់មក ប្រសិនស្នាដៃត្រូវបានជាប់ចំណាត់ថ្នាក់ CHRISTIE'S នឹងធ្វើការបោះពុម្ពផ្សាយជាកាតាឡុក ដែលមានចុះផ្សាយជារូបភាពស្នាដៃរួមជាមួយនឹងការពណ៌នាដ៏ខ្លីមួយអំពីស្នាដៃ និងអត្ថបទខ្លីសរសេររៀបរាប់អំពីជីវប្រវត្តិសង្ខេបរបស់បុគ្គលដែលជាម្ចាស់ស្នាដៃ។ អំឡុងពេលធ្វើការចុះផ្សាយនូវកាតាឡុកទាំងនេះ CHRISTIE'S បានបើកឱកាសដល់អតិថិជនទាំងឡាយណាដែលចាប់អារម្មណ៍ និងមានបំណងដេញថ្លៃយកស្នាដៃនោះ អោយដេញថ្លៃយក ចំណែកឯប្រាក់ដែលទទួលបាន ត្រូវបានយកជាអំណោយសប្បុរសធម៌ជូនដល់អង្គការពីរ គឺ Cambodia 2000 និង Amrita Performing Arts ដែលមាននាទីផ្តត់ផ្គង់ផ្នែកវិចិត្រសិល្បៈ។ អ្វីទាំងនេះហើយ ដែលស្តែងឲ្យឃើញអំពីការរួមចំណែកនៅក្នុងការលើកកម្ពស់វិស័យសិល្បៈនៅប្រទេសកម្ពុជា ដោយមានលក្ខណៈជាសប្បុរសធម៌។ ហេតុដូច្នោះហើយ ក្នុងនាមយើងជាយុវជនខ្មែរដែលជាទំពាំងស្នងឫស្សី ស្នងកេរ្តិ៍តំណែលស្នាដៃដូនតា គប្បីចូលរួមអោយបានមោះមុតក្នុងការលើកតម្កើងស្នាដៃរបស់ខ្លួនឯងអោយកាន់តែរីកសុះសាយឡើងៗពេញផ្ទៃប្រទេស និងពិភពលោក។ម៉្យាងវិញទៀត នេះជាឱកាសកម្រមួយដែលសិល្បករ និងវិចិត្រករទាំងអស់ទន្ទឹងរង់ចាំ៕



*by Sophatra*